# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០១-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១០៥ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម LEE Han-Gon អតីតឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃ សាធារណរដ្ឋកូរ៉េប្រចាំព្រះរាជាណាចក្រកម្ពុជា ពីខែ កក្កដា ឆ្នាំ ២០០៣ ដល់ខែ កុម្ភៈ ឆ្នាំ ២០០៦ នូវ គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ១៣៤៥

០៤-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១១ ស្ដីពីការ បញ្ចប់តំណែងសម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាលនិងសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១៣៤៦

០៤-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១១២ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ១៣៤៧


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


០២-៣-២០០៦ -អនុក្រឹត្យលេខ ២២ អនក្រ.បក ស្ដីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ១៣៤៨

០៣-៣-២០០៦ -អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្ដីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះប្រធានការិយាល័យប្រជាពលរដ្ឋ របស់រដ្ឋបាលស្រុកសាកល្បង ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ១៣៥១

០៣-៣-២០០៦ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្ដីពីវិសោធនកម្មមាត្រា ៣.ក នៃអនុក្រឹត្យលេខ ៧៣ អនក្រ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៣ ស្ដីពីការកែប្រែអត្រាពន្ធគយអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាត ១៣៥៣

០៧-៣-២០០៦ -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្ដីពីការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ទៅជា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ១៣៥៥

០៧-៣-២០០៦ -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្ដីពីការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង ទៅជា សាកលវិទ្យាល័យ បច្ចេកវិទ្យា និងគ្រប់គ្រង ១៣៥៨

០៣-៣-២០០៦ -អនុក្រឹត្យលេខ ១៤៧ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣៦១

០៥-៣-២០០៦ -អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ស្តីពីការបញ្ចប់តំណែងនាយនគរបាលជាតិជាន់ខ្ពស់ ១៣៦២

០៦-៣-២០០៦ -អនុក្រឹត្យលេខ ១៤៩ អនក្រ.បក ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ ១៣៦៣

០៧-៣-២០០៦ -អនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ១៣៦៤

០៧-៣-២០០៦ -អនុក្រឹត្យលេខ ១៥១ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៣៦៥

០៧-៣-២០០៦ -អនុក្រឹត្យលេខ ១៥២ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣៦៦

## ២-សេចក្តីសំរេច

០១-៣-២០០៦ -សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១៣៦៧

០៣-៣-២០០៦ -សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៣៧០

០៥-៣-២០០៦ -សេចក្តីសំរេចលេខ ០៥ សសរ ស្តីពីការបង្កើតគណៈកម្មការស្តារនិងប្រមូលយកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃនៅក្នុងសមុទ្រ ខេត្តកោះកុង ១៣៧១

០៧-៣-២០០៦ -សេចក្តីសំរេចលេខ ០៦ សសរ ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍តំបន់កសិ-ទេសចរណ៍ វប្បធម៌ នៃអតីតព្រះបរមរាជវាំងចាស់ " ហ្លួងព្រះស្តេចកន " ស្ថិតក្នុងឃុំជូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ១៣៧៣

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២២-០២-២០០៦ -ប្រកាសលេខ ១៣៩ សហវ.ប្រក ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៦ ១៣៧៥

២២-០២-២០០៦ -សេចក្តីជូនដំណឹងលេខ ០០៦ សហវ.ពដ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៦ ១៣៨៥

## ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

២៧-០១-២០០៦ -លិខិតលេខ ៣៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេស គ្រុប** ១៣៨៧

២៧-០១-២០០៦ -លិខិតលេខ ៣៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខ្មែរ មេគយើរ** ១៣៨៩

២៧-០១-២០០៦ -លិខិតលេខ ៣៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេចឌី ស្តារ ម៉ាញូនីង** ១៣៩១

៣០-០១-២០០៦ -លិខិតលេខ ៣៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យ៉ាំង ដ្រេហ្គន អ៊ីមផិច** ១៣៩៣

៣០-០១-២០០៦ -លិខិតលេខ ៣៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្វសហ្វេត & ខេមីខល (ខេមបូឌា)** ១៣៩៥

៣០-០១-២០០៦ -លិខិតលេខ ៣៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជី តៃ សូរីង ត្រេត** ១៣៩៧

៣០-០១-២០០៦ -លិខិតលេខ ៣៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឆែកបូ គ្រុប** ១៣៩៩

៣០-០១-២០០៦ -លិខិតលេខ ៣៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **(ខេមបូឌា) ខសភើ ខមភេនី** ១៤០១

៣០-០១-២០០៦ -លិខិតលេខ ៣៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ឡាក់ឃី ម៉ាន់នី រីមីថិនស៍** ១៤០៣

៣០-០១-២០០៦ -លិខិតលេខ ៣៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃីងវែល ត្រេឌីង ខមភេនី លីមីធីត** ១៤០៥

៣១-០១-២០០៦ -លិខិតលេខ ៣៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ាង សេងហ៊ត់** ១៤០៧

៣១-០១-២០០៦ -លិខិតលេខ ៣៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីហ្សុយហ្វូ សេនស៍ អ៊ិនធើណេសិនណល** ១៤០៩

៣១-០១-២០០៦ -លិខិតលេខ ៣៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.ធី.អេស អេប្រ្កី~អ៊ីមផត អិចផត & ហ្វេកធើរី** ១៤១១

៣១-០១-២០០៦ -លិខិតលេខ ៣៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពូន គូក** ១៤១៣

០១-០២-២០០៦ -លិខិតលេខ ៣៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីនជេស អ៊ិនធើណេសិនណល អ៊ីន** ១៤១៥

០១-០២-២០០៦ -លិខិតលេខ ៣៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពេជ្រ សម្បត្តិ ខូ អិលធីឌី** ១៤១៧

០១-០២-២០០៦ -លិខិតលេខ ៣៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គុណា ដានី ធួរ** ១៤១៩

០២-០២-២០០៦ -លិខិតលេខ ៤០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឱុកសាន ម៉ាញនីខ** ១៤២១

០២-០២-២០០៦ -លិខិតលេខ ៤០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.អេ.ឌី គ្រុប ខូ អិលធីឌី** ១៤២៣

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

## ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម LEE Han-Gon អតីតឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណៈរដ្ឋកូរ៉េ
ប្រចាំព្រះរាជាណាចក្រកម្ពុជា ពី ខែ កក្កដា ឆ្នាំ ២០០៣ ដល់ ខែ កុម្ភៈ ឆ្នាំ ២០០៦

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៤-០៦០៣-១១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦

លេខៈ ១០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ឌីតាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់តំណែងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៦០៣-១១៦

លេខ: ១០៧ ច.ល

**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៦

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី៤ នីតិកាលទី៣នៃរដ្ឋសភា នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតសំដែងការទុកចិត្តលើការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

-ឯកឧត្តម **ចាន់ សុទ្ធសិក្តិ** ជារដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម
ជំនួសឯកឧត្តម **សុក ស៊ីផាន់ណា** ដែលបានសុំលាលែង

-ឯកឧត្តម **ឆង់ សារ៉េត** ជារដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម
ជំនួសឯកឧត្តម **អ៊ុំ គីមហ៊ាង** ដែលបានទទួលមរណភាព ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣:** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៦០៣-១១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៦

លេខ:១១១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...២៧២...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ

## រា ជ រ ដ្ឋា ភិ បា ល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤០អនក្រ បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុង នៅតាមស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាមច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

**មាត្រា២ :**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងជាស្ថាប័នចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៣ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃជាសេនាធិការផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ មានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ គ្មានការហាមប្រាម គ្មានការរារាំងក្នុងការពិនិត្យឡើងវិញលើបញ្ជីកត់ត្រា.ចំណូលចំណាយថវិកា.ទ្រព្យសម្បត្តិ និង បញ្ជីបុគ្គលិករបស់អង្គភាពទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា៤ :**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃមានភារកិច្ចសំខាន់ៗដូចតទៅ :

-ធ្វើផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំឱ្យមានភាពសមស្របច្បាស់លាស់គ្រប់គ្រាន់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ និងសំរេច ។

-ពិនិត្យឡើងវិញលើការអនុវត្តច្បាប់ បទបញ្ញា វិន័យថវិកា និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការ ហិរញ្ញវត្ថុពិសេសការកៀរគរ និងគ្រប់គ្រងចំណូល ការចំណាយ ថវិកាហិរញ្ញប្បទាន និងបំណុល ។

- ធ្វើការវាយតម្លៃផែនការ និង សកម្មភាពសវនកម្មផ្ទៃក្នុង ដែលបានចាត់ចែងកន្លងមក ។

- ធ្វើរបាយការណ៍ និង សេចក្តីសន្និដ្ឋាននៃសវនកម្មផ្ទៃក្នុងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។

-ពិនិត្យឡើងវិញលើគ្រប់ពត៌មានហិរញ្ញវត្ថុ និង កិច្ចប្រតិបត្តិការនានា ដើម្បីធានាភាពច្បាស់លាស់ជឿទុកចិត្ត និង ទាន់ពេលវេលា ។

-ពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិដែលបានបង្កើត ដើម្បីធានាលើកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ។

- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ ។

- ពិនិត្យឡើងវិញលើកម្មវិធីនៃកិច្ចប្រតិបត្តិការគំរោងចំណាយមូលធនដើម្បីធានាបានតាមគោលបំណង និងផែនការដែលបានដាក់ចុះ ។

- ពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងភាពសន្សំសំចៃ ដើម្បីមានវិធានការកែលំអ ។

- សំរបសំរួលការងារ និងសហប្រតិបត្តិការជាមួយអគ្គាធិការដ្ឋាន អាជ្ញាធរសវនកម្មជាតិ និងស្ថាប័នពាក់ព័ន្ធ ។

- ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

- បំពេញកិច្ចការផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា៥ :**

-នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ដឹកនាំ និងគ្រប់គ្រងដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

-ចំនួនការិយាល័យនានាចំណុះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកកំណត់ ។

-ប្រធាន អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាន និងអនុប្រធានការិយាល័យចំណុះត្រូវតែជាមន្ត្រីក្នុងក្របខណ្ឌ ហើយមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សា ឬ សញ្ញាប័ត្រសមមូលផ្នែកគណនេយ្យ ឬ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ មានបទពិសោធន៍ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ឬ គ្រប់គ្រងរដ្ឋបាលសាធារណៈយ៉ាងតិច ៥ឆ្នាំឡើងទៅ ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៦ :**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៦**

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចមាត្រា៧ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះប្រធានការិយាល័យប្រជាពលរដ្ឋ របស់រដ្ឋបាលស្រុកសាកល្បង ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែ ដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលស្តីពីកម្មវិធីសាកល្បង និង ប្រព័ន្ធ គ្រប់គ្រងរដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាល ស្រុកសាកល្បង ស្រុកសៀមរាប ខេត្ត សៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ស្មើនឹងប្រាក់ បំណាច់មុខងារកម្រិត ១ របស់អភិបាលរងស្រុក ខ័ណ្ឌ ។

**មាត្រា ២.-** ប្រាក់ឧបត្ថម្ភដែលបានកំណត់ក្នុងមាត្រា ១ ខាងលើនឹងត្រូវអនុវត្តចំពោះប្រធានការិយាល័យប្រជាពលរដ្ឋគ្រប់ស្រុក ខ័ណ្ឌ ដែលរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងតាមគំរូនៃសេចក្ដីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-** ប្រាក់ឧបត្ថម្ភរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវផ្ដល់ជូនតែក្នុងរយៈពេលនៃមុខតំណែង និង ត្រូវចាប់អនុវត្តក្រោយពីមានដីកាតែងតាំងជាផ្លូវការរបស់អភិបាលខេត្ត ក្រុង ។

**មាត្រា ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា៥*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## វិសោធនកម្មមាត្រា ៣.ក នៃអនុក្រឹត្យលេខ ៧៣ អនក្រ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាត

---*---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសំរួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ ចុះថ្ងៃទី១៧ វិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច :

**មាត្រា១.-** ត្រូវបានធ្វើវិសោធនកម្មមាត្រា ៣.ក នៃអនុក្រឹត្យលេខ៧៣ អនក្រ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត ដូចខាងក្រោម :

- **មាត្រា ៣.ក ថ្មី** : ៣ ភាគរយ សម្រាប់សេវាទូរស័ព្ទក្នុង និងក្រៅប្រទេស ។

**មាត្រា២.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៦ នេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦

**ហ៊ុន សែន**

**បានយកសេចក្តីក្រាបបង្គំជូន**

**សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ២៥ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ទៅជា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការបង្កើត វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៣៩២ ស្មន អយក.ឧស ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ទៅជា **សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច** " University of Management and Economics " ហៅកាត់ជាភាសាខ្មែរ " ស.គ.ស " និងហៅកាត់ជាភាសាអង់គ្លេស " UME "។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ៧៤ ក្រុមទី៤ ភូមិព្រែកព្រះស្តេច ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបច្ចុប្បន្នមានសាខាចំនួន ៥កន្លែង នៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត ដូចជា : នៅខេត្តកំពង់ចាម ខេត្តកំពត ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ និងក្រុងព្រះសីហនុ។

**មាត្រា ២ :** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងសាខាទាំងអស់របស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣ :** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស ឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- រៀបចំកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សាវិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រតាមឯកទេសរបស់សាកលវិទ្យាល័យ។
- កសាងផែនការអភិវឌ្ឍសម្រាប់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- គ្រប់គ្រង និយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

**មាត្រា ៤ :** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំឱ្យមាន មហាវិទ្យាល័យ ចំនួន ៥ គឺ :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច អាចបើក មហាវិទ្យាល័យ ឬសាខា ឬឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥** : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល របស់ ស.គ.ស និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧** : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវគ្រប់គ្រងដោយ សាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨** : សាកលវិទ្យាធិការមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៩** : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ហើយមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្ត តាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១០** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថាន បច្ចេកវិទ្យានិងគ្រប់គ្រង ទៅជា សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត វិទ្យាស្ថាន បច្ចេកវិទ្យា និងគ្រប់គ្រង
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២៩១៤ អយក.ឧស ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

# ស ម្រេ ច

**មាត្រា ១** : ទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថាន បច្ចេកវិទ្យានិងគ្រប់គ្រង ទៅជា**សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង** " **University of Technology and Management** " ហៅកាត់ជាភាសាខ្មែរ " **ស.ប.គ** " និងហៅកាត់ជាភាសាអង់គ្លេស " **UTM** "។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអគារលេខ ៥៥ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២** : សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស ឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង។
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិនិងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សា ឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងឯកទេសរបស់សាកលវិទ្យាល័យ។
- កសាងផែនការអភិវឌ្ឍសម្រាប់ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង។
- គ្រប់គ្រង និយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ។

**មាត្រា ៣** : សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំឱ្យមាន មហាវិទ្យាល័យ ចំនួន ៥ គឺ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យ នីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យ កសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង អាចបើក មហាវិទ្យាល័យ ឬសាខា ឬឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤** : សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា ៥ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យនេះ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៦ :** សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាធិការមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ។
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៨ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ សាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ហើយមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្ត តាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ បច្ចេកវិទ្យានិងគ្រប់គ្រង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១៤៧...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលក្រុងប៉ៃលិន

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្នុងក្រុងប៉ៃលិន ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-លោក **គុំ វ៉ាន់តារា**

២-លោកជំទាវ **ចាន ស្រីមុំ**

៣-លោក **ឃ្លោក នួយ**

សប្បុរសជនទាំង០៣រូបខាងលើ បានបរិច្ចាគ ថវិការួម ចំនួន ៤៨.៨២៧,២៥ ដុល្លារ

៤-ឯកឧត្តម ឧត្តមសេនីយ៍ **ពៅ សាវ៉ាន់** ថវិកា ចំនួន ១០.៧៦២ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកយាយ **អាន** ថវិកា ចំនួន ៩.៤៧០,៥០ ដុល្លារ

២-លោក វរសេនីយ៍ឯក **យឹម ឡាំង** ថវិកា ចំនួន ៥.៣៥៦ ដុល្លារ

៣-លោក វរសេនីយ៍ត្រី **ឌី សុខា** ថវិកា ចំនួន ៥.២១៣ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលក្រុងប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១៤៨...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការបញ្ចប់តំណែងនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១:** ត្រូវបានបញ្ចប់តំណែង ឧត្តមសេនីយ៍ឯក **សៅ វ៉ានី** អត្តលេខ ០៤០៤ ជាអគ្គស្នងការរងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ ._**

ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ទោ ជួន ម៉ាឆឺន អត្តលេខ ២០៤១៥ ជំនួយការឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ា សឿន នាយករងសាលាភូមិន្ទនគរបាល នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....១៥០....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន ០២គ្រឿង ជូនប្រធានគំរោង និងអ្នកដឹកនាំការស្រាវជ្រាវ នៃសាកលវិទ្យាល័យ វ៉ាសេដា ប្រទេសជប៉ុន ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការលើគំរោងជួសជុលប្រាសាទនានា នៅតំបន់ប្រាសាទសំបូរព្រៃគុក ក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

- លោកបណ្ឌិតសាស្ត្រាចារ្យ **ណាកាហ្គាវ៉ា តាកេស៊ី** ( Mr.Nakagawa Takeshi) ប្រធានគំរោង

**ខ-មេដាយសហមេត្រី ថ្នាក់ អស្សរិទ្ធិ :**

- លោក **អ៊ីឈីតា ស៊ីមូដា** ( **Mr.Ichita Shimoda** ) អ្នកដឹកនាំការស្រាវជ្រាវ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា ១ ៖** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកស្រី **សូ សុគន្ធារី** (**Mrs. So Sokuntheary**) ប្រធានក្រុមអភិរក្ស ដែលមានស្នាដៃល្អក្នុងការអនុវត្តគំរោងជួសជុលប្រាសាទនានា ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ ។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី និងសប្បុរសជន ចំនួន ០៥រូប ដែលបានជួយកសាងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០៣ខ្នង មានឈ្មោះថា " *មណ្ឌលថ្ងៃល្អ* " ស្ថិតនៅភូមិព្រែកជំ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចំណាយអស់ថវិកា ចំនួន ៦៩.០៨៦ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម Fumiaki Takahashi ឯកអគ្គរាជទូតជប៉ុន

២-កញ្ញា **លី សុវណ្ណារី** នាយិកាមជ្ឈមណ្ឌល ថែទាំសុខភាពកុមារ ( HCC )

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **កែវ សារ៉ាវុធ** នាយរដ្ឋបាល និងហិរញ្ញវត្ថុ មជ្ឈមណ្ឌល HCC

២-លោក **ស៊ិន វិរៈ** អ្នកសម្របសម្រួលការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី មជ្ឈមណ្ឌល HCC

៣-លោក **វ៉ែន សារឿន** ប្រធាន *មណ្ឌលថ្ងៃល្អ* មជ្ឈមណ្ឌល HCC

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៣ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមការចាំបាច់ ក្នុងការកែទំរង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល និងយោងទៅតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# **សំ រេ ច**

**ប្រការ១ :** ត្រូវបានបង្កើត "ក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ហៅកាត់ថា "ក្រុមការងារ ក.យ.ឧ.ក្រ.ច." សំរាប់ជួយរដ្ឋមន្ត្រី ក្នុងទំនាក់ទំនងការងារជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការប្រព្រឹត្តទៅរបស់ខ្លួន ។

**ប្រការ២ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." នេះមានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើទំនាក់ទំនង និងសម្របសម្រួលកិច្ចការរវាងក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំដៅធ្វើឱ្យដំណើរការ នៃប្រព័ន្ធតុលាការប្រព្រឹត្តទៅបានល្អប្រសើរ និងឯកភាពគ្នា ។
- ទទួលបន្ទុកគ្រប់កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។
- ទទួលបន្ទុករៀបចំធ្វើរបាយការណ៍ កំណត់ហេតុ នៃកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងថែរក្សាទុកនូវរបាយការណ៍ កំណត់ហេតុទាំងនោះ ព្រមទាំងឯកសារផ្សេងៗទៀត ។

**ប្រការ៣ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន រដ្ឋលេខាធិការមួយរូបជាអនុប្រធាន និងមានសមាជិកមួយចំនួនជាសេនាធិការតាមការចាំបាច់ ហើយដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ ។

**ប្រការ៤ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." មានពីរផ្នែកគឺ : ផ្នែករដ្ឋបាល-ហិរញ្ញវត្ថុ និងផ្នែកជំនួយកិច្ចការតុលាការ ។

**ប្រការ៥ :** ប្រធានផ្នែក អនុប្រធានផ្នែក មន្ត្រីបុគ្គលិកនៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**ប្រការ៦ :** មន្ត្រី បុគ្គលិក នៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." មានប្រាក់បៀវត្ស ដូចមន្ត្រី បុគ្គលិក ដែលមានថ្នាក់ស្មើគ្នារបស់ក្រសួងយុត្តិធម៌ និងមានប្រាក់ឧបត្ថម្ភផ្សេងៗ ដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**ប្រការ៧** : ថវិកាសំរាប់ដំណើរការនៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ត្រូវគ្រោងក្នុងថវិកាជាតិ ដែលស្ថិតនៅជាកញ្ចប់ថវិកាមួយដោយឡែក នៃថវិកាក្រសួងយុត្តិធម៌ ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអាណាប័ក ។

**ប្រការ៨** : របាយការណ៍ កំណត់ហេតុ និងឯកសារផ្សេងៗទាំងអស់ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរក្សាទុកនៅទីស្នាក់ការរបស់ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ដែលមានទីតាំង នៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

សមាជិក សមាជិកា នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសិទ្ធិពិនិត្យមើលរាល់ឯកសារទាំងអស់ ដែលរក្សាទុកនៅក្នុងទីស្នាក់ការរបស់ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ។

**ប្រការ៩** : "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សំរាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ១០** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារសាមី ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ[illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង
ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន រដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចប្រការ១១
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ អនក្រ.សសរ

# សេចក្តីសំរេច

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/៨៤ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **សេង វ៉ាឡាត់** ទីប្រឹក្សាផ្ទាល់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ស ខេង) ឱ្យទទួលការងារតាមដានការអនុវត្តន៏ការងារគ្រប់វិស័យ នៅខេត្តបាត់ដំបង ។

**ប្រការ ២ :** ឯកឧត្តម **សេង វ៉ាឡាត់** ត្រូវរាយការណ៏អំពីសភាពការណ៏លេចធ្លោ បញ្ហាប្រឈម និងសំណូមពរនានានៅខេត្តបាត់ដំបង ព្រមទាំងវិធានការដោះស្រាយ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ឱ្យបានជាប្រចាំ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អភិបាលខេត្តបាត់ដំបង និងឯកឧត្តម **សេង វ៉ាឡាត់** ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៦

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៥...ស.សរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការស្តារ និងប្រមូលយកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃនៅក្នុងសមុទ្រ ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីស្តារ និងប្រមូលយកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃដែលលិចនៅក្នុងសមុទ្រក្នុងដែនដីខេត្តកោះកុងដែលមានសមាសភាពដូចខាងក្រោម÷

- ឯកឧត្តមនាយឧត្តមសេនីយ៍ ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ ប្រធាន
- ឯកឧត្តម យុទ្ធ ភូថង អភិបាលខេត្តកោះកុង អនុប្រធាន
- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម លី យ៉ុងផាត់ បេសកជនពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម ឆឹយ រឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក
- ឧត្តមសេនីយ៍ឯក ចាន់ អ៊ាន ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ សមាជិក
- ឧត្តមសេនីយ៍ទោ តេង ឈួន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឧត្តមនាវីត្រី កែវមុនី ស៊ូកា បញ្ជាការរងកងទ័ពជើងទឹក សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាត់ និងវត្ថុបុរាណមានតម្លៃដែលបានស្តារ និងស្រង់រួចហើយ ព្រមទាំងជំរុញការបន្តស្រង់យកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃទាំងអស់ពីបាតសមុទ្រនៃមូលដ្ឋាន ខេត្តកោះកុង ដើម្បីយកមកតម្កល់ទុកជាបណ្តោះអាសន្ន ក្នុងខេត្តកោះកុងរង់ចាំការសំរេចពីរាជរដ្ឋាភិបាល ។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** ចំពោះមធ្យោបាយ និងថវិកាសំរាប់ប្រើប្រាស់ក្នុងកិច្ចការនេះ គណៈកម្មការត្រូវសហការជាមួយឯកឧត្តម លី យ៉ុងផាត់ បេសកកជនពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤ :** សមាជិកគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :....០៩....សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍តំបន់កសិ-ទេសចរណ៍ វប្បធម៌ នៃអតីតព្រះបរមរាជវាំងចាស់ "ល្វង់ព្រះស្តេចកន" ស្ថិតក្នុងឃុំជួនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៩ / ០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**សំ រេ ច**

**ប្រការ ១** : សមាសភាពគណៈកម្មការអភិវឌ្ឍន៍តំបន់កសិ-ទេសចរណ៍ វប្បធម៌ នៃអតីតព្រះបរមរាជវាំងចាស់ "**ល្វង់ព្រះស្តេចកន**" មានរាយនាមដូចតទៅ :

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- ឯកឧត្តម **នុត ណារ៉ាង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ អនុប្រធាន

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | **ជុំ តើង** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- ឯកឧត្តម | **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រី ក្រសួងព័ត៌មាន | សមាជិក |
| ៥- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម | **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម | **តេង ឡៅ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- ឯកឧត្តម | **សាត សាមី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- ឯកឧត្តម | **ហ៊ុន ណេង** | អភិបាលខេត្តកំពង់ចាម | សមាជិក |
| ១០- ឯកឧត្តម | **អ៊ុង សាមី** | អភិបាលខេត្តព្រៃវែង | សមាជិក |
| ១១- លោកឧកញ៉ា | **ស៊ឹម វណ្ណា** | អគ្គនាយកចំការកៅស៊ូបឹងកេត | សមាជិក |
| ១២- លោក | **ស៊ុន សុខលី** | អភិបាលស្រុកពញាក្រែក | សមាជិក |
| ១៣- លោក | **ស៊ឹម ស៊ីថូវ** | អភិបាលស្រុកត្បូងឃ្មុំ | សមាជិក |
| ១៤- លោក | **ឃុន ថា** | អភិបាលស្រុកអូររាំងឪ | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ចរៀបចំអភិវឌ្ឍន៍តំបន់ នៃអតីតព្រះបរមរាជវាំងចាស់ **"ឃ្លាំងព្រះស្តេចកន"** ស្ថិតក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ឱ្យក្លាយជាតំបន់កសិ-ទេសចរណ៍ វប្បធម៌ ។

**ប្រការ ៣** : សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៦ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
## សំរាប់ឆ្នាំ ២០០៦

ទទួលបាន
ថ្ងៃទី ០៩ ខែ ៣ ឆ្នាំ ០៦

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ ឆ្នាំ២០០៦ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax: 855-23-427 798

**សំរេច :**

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ត្រូវប្រមូលចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៦ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងបង្ហាញ និង ប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូននិងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ រួចហើយ ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០០៥ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ ២០០៥ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ ២០០៥ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ ២០០៥រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ក្រុងនៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ ២០០៥ ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយាន ជំនិះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះនេះត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យ របស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណសំគាល់មួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដែលត្រូវថែរក្សាទុកកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និង ទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ ២០០៧ ។

**ប្រការ៨.-** សំរាប់ឆ្នាំ ២០០៦ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទមានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងចតុកោណ :**

នៅខាងលើបំផុតនៃប័ណ្ណមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលមានលេខ "២០០៦" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធរថយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៦" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធរថយន្ត" មានសរសេរចំនួនប្រាក់ពន្ធ។ ខាងក្រោមលេខកំណត់ចំនួនទឹកប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ នៅផ្នែកខាងមុខប័ណ្ណ មានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ។

ប័ណ្ណរាងចតុកោណនេះមាន ១២ ពណ៌គឺ :

- **ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :**
  - \+ ត្រាក់ទ័រមានកម្លាំង ៣៥ សេះ
  - \+ ត្រាក់ទ័រមានកម្លាំង ៦៥ សេះ
  - \+ ត្រាក់ទ័រមានកម្លាំង ៨២ សេះ
- **ប័ណ្ណពណ៌លឿងខ្ចី ប្រើសំរាប់ :**
  - \+ រថយន្តទេសចរណ៍កម្លាំងដល់ ៩ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**
  - \+ រថយន្តទេសចរណ៍កម្លាំង ៩ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
  - \+ រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតលើស ៥ ឆ្នាំ
- **ប័ណ្ណពណ៌ផ្ទៃមេឃ ប្រើសំរាប់ :**
  - \+ រថយន្តដឹកទំនិញដល់ ៣ តោន
  - \+ រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  - \+ រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
- **ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**
  - \+ រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**
  - \+ រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- **ប័ណ្ណពណ៌ស ប្រើសំរាប់ :**
  - \+ រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន
  - \+ រ៉ឺម៉កសណ្តោង ដល់ ១០ តោន

+ រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- **ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**

+ រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន

+ រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន·

- **ប័ណ្ណពណ៌បៃតងឆ្នូតត្រួយចេក ប្រើសំរាប់ :**

+ រថយន្តដឹកទំនិញលើសពី ២០ តោន

+ រ៉ឺម៉កសណ្តោងលើសពី ២០ តោន

- **ប័ណ្ណពណ៌លឿងទុំឆ្នូតផ្កាឈូក ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ

- **ប័ណ្ណពណ៌ខៀវឆ្នូតផ្ទៃមេឃ ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- **ប័ណ្ណពណ៌ក្រហមឆ្នូតលឿងខ្ចី ប្រើសំរាប់ :**

+ រថយន្តទេសចរណ៍កម្លាំងលើសពី ២៤សេះ ឡើងទៅ

**២. ប័ណ្ណរាងឆកោណ :**

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៦" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៦" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" រាងឆកោណ ពណ៌លឿងខ្ចី និង ពណ៌ស្វាយ មានសរសេរចំនួនទឹកប្រាក់ពន្ធ ខាងក្រោមលេខកំណត់ចំនួនទឹកប្រាក់ពន្ធ មានសរសេរ លេខរៀងនៃប័ណ្ណនីមួយៗ ។ ដោយឡែកប័ណ្ណរាងឆកោណពណ៌ផ្កាឈូក ពុំមានចារិកចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងឆកោណនេះមាន ៣ ពណ៌គឺ :

- **ប័ណ្ណពណ៌លឿងខ្ចី ប្រើសំរាប់ :**

+ ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ $សម^3$

- **ប័ណ្ណពណ៌ស្វាយ ប្រើសំរាប់ :**

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០$សម^3$ ទៅ ១២៥ $សម^3$

- **ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ $សម^3$ ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧,៥០០ រៀល

+ ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ ដែលមានទឹកប្រាក់ពន្ធចំនួន ១៥,០០០ រៀល

៣. ប័ណ្ណរាងត្រីកោណ :

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានអក្សរ និងលេខ "២០០៦" សញ្ញារូបហង្ស និងមានអក្សរ "ប័ណ្ណបង់ពន្ធជលយាន" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៦" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធជលយាន" មានលេខរៀងនៃប័ណ្ណនីមួយៗ ។ ប័ណ្ណរាងត្រីកោណនេះ ពុំមានចារិកចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងត្រីកោណនេះមាន ៣ ពណ៌គឺ :

- **ប័ណ្ណពណ៌លឿងខ្ចី ប្រើសំរាប់ :**
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛
- **ប័ណ្ណពណ៌ស្វាយ ប្រើសំរាប់ :**
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛
- **ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

**ប្រការ៩.-** ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុបដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក(ទំនិញ-មនុស្ស)។

- ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០.០០០៛ ។
- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០.០០០៛ ។
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- និងរ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០.០០០៛ ។

**ប្រការ១០.-** យានយន្តគ្រប់ប្រភេទដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ហើយបានលក់ទៅឱ្យអ្នកផ្សេង ករណីនេះត្រូវកំណត់ឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៥ និងបង់ប្រាក់ពិន័យតាមច្បាប់ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ។

**ប្រការ១១.-** ចាប់ពីថ្ងៃទី.០១ ខែ កក្កដា ឆ្នាំ ២០០៦ នេះតទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៦ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៦ នេះ ។

ការត្រួតពិនិត្យនឹងត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយក្នុងភូមិ ឃុំ សង្កាត់ .... និង ទីចំណតនានា ។

**ប្រការ១២.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

## តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
## ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

( តារាងឧបសម្ព័ន្ធទី I )

ភ្ជាប់ជាមួយប្រកាសលេខ..១៣៥..ប្រក.សហវ.ពដ ចុះថ្ងៃទី២២..ខែកុម្ភៈ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកតា: រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] : | | |
| + ដល់ ៣ តោន | 150 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) : | | |
| + ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | 250 000 | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥ កៅអី | 200 000 | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | 150 000 | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + កម្លាំងដល់ ៩ សេះ | 100 000 | 80 000 |
| + កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ | 150 000 | 100 000 |
| + កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ | 250 000 | 180 000 |
| + កម្លាំងលើសពី ១៧ សេះ ដល់ ២៤ សេះ | 800 000 | 600 000 |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | |
|---|---|
| + កម្លាំងលើសពី ២៤ សេះ ឡើងទៅ | 1 000 000 |
| - ត្រាក់ទ័រកម្លាំង ៨៧ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 50 000 |
| - ត្រាក់ទ័រកម្លាំង ៦៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 40 000 |
| - ត្រាក់ទ័រកម្លាំង ៣៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 30 000 |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម³ | 3 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ ស.ម³ ដល់ ១២៥ ស.ម³ | 4 500 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម³ ឡើងទៅ | 7 500 |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | 15 000 |
| ***ជលយាន ឬជលយានយន្តផ្លូវទន្លេ*** : | |
| - ជលយានដឹកទំនិញ : | |
| + ដល់ ៣ តោន | 50 000 |
| + លើសពី ៣ តោន ដល់ ១០ តោន | 100 000 |
| + លើសពី ១០ តោន ដល់ ២០ តោន | 200 000 |
| +លើសពី ២០ តោន | 300 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 200 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | 300 000 |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ៥០ សេះ | 20 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 30 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 50 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | 60 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | 180 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ឡើងទៅ | 300 000 |
| - កាណូតនេសាទមានកំលាំងដល់ ៥០ សេះ | 10 000 |
| - កាណូតនេសាទមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 20 000 |
| - កាណូតនេសាទមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 30 000 |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្គង " | 10 000 |
| - អូប័រមានកំលាំងដល់ ២៥ សេះ | 150 000 |
| - អូប័រមានកំលាំងលើសពី ២៥ សេះ ដល់ ៤០ សេះ | 200 000 |
| - អូប័រមានកំលាំងលើសពី ៤០ សេះ ដល់ ៨០ សេះ | 300 000 |
| - អូប័រមានកំលាំងលើសពី ៨០ សេះ ដល់ ២០០ សេះ | 400 000 |

| | |
|---|---|
| - អូប័រមានកំលាំងលើសពី ២០០ សេះ ឡើងទៅ | 500 000 |
| **ជលយាន ឬជលយាន្តយន្តផ្លូវសមុទ្រ** : | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 150 000 |
| - ទូកដឹកទំនិញដល់ ១០០ តោន | 200 000 |
| - ទូកនេសាទដែលមានកំលាំងសេះដល់ ៩ សេះ | 10 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ១០ សេះ ដល់ ២០ សេះ | 15 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ២១ សេះ ដល់ ៤០ សេះ | 25 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ៤១ សេះ ដល់ ៨០ សេះ | 50 000 |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទូកនេសាទដែលមានកំលាំងសេះពី ៨១ សេះ ដល់ ១៥០ សេះ | 70 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ១៥១ សេះ ឡើងទៅ | 100 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេះ | 10 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ១៣ សេះ ដល់ ៥០ សេះ | 20 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ៥១ សេះ ឡើងទៅ | 50 000 |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | 300 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | 750 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | 1 200 000 |
| - កប៉ាល់នេសាទមានកំលាំងដល់ ១៥០ សេះ | 300 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | 400 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 600 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | 1 200 000 |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ២៥០ សេះ | 200 000 |
| - កប៉ាលសណ្តោងមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 400 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | 600 000 |

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ .................. សហវ.........

## ឧបសម្ព័ន្ធកំណត់កំលាំងសេះរបស់រថយន្តទេសចរណ៍
(តារាងឧបសម្ព័ន្ធទី II)

ភ្ជាប់ជាមួយប្រកាសលេខ ១៣៩ ប្រក.សហវ.ពដ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| ល.រ | រថយន្តទេសចរណ៍ដែលប្រើប្រាស់ ថាមពលសាំង ឬ មាហ្សូត | ចំនួន CC "វ៉ូលូម" | កំលាំងគិតជាសេះ | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ | |
| ១ | រថយន្តទេសចរណ៍ | ដល់ ១ ៥០០ CC | ដល់ ៩ សេះ | ១០០ ០០០ | ៨០ ០០០ | និយមហៅ ១.៥ |
| ២ | រថយន្តទេសចរណ៍ | លើសពី ១ ៥០០ CC ដល់ ២ ០០០ CC | លើសពី ៩ សេះ ដល់ ១២ សេះ | ១៥០ ០០០ | ១០០ ០០០ | និយមហៅ ១.៦ ដល់ ២ |
| ៣ | រថយន្តទេសចរណ៍ | លើសពី ២ ០០០ CC ដល់ ២ ៩០០ CC | លើសពី ១២ សេះ ដល់ ១៧ សេះ | ២៥០ ០០០ | ១៨០ ០០០ | និយមហៅ ២.២ ដល់ ២.៩ |
| ៤ | រថយន្តទេសចរណ៍ | លើសពី ២ ៩០០ CC ដល់ ៤ ០០០ CC | លើសពី ១៧ សេះ ដល់ ២៤ សេះ | ៨០០ ០០០ | ៦០០ ០០០ | និយមហៅ ៣ ដល់ ៤ |
| ៥ | រថយន្តទេសចរណ៍ | លើសពី ៤ ០០០ CC ឡើងទៅ | លើសពី ២៤ សេះ ឡើងទៅ | ១ ០០០ ០០០ | | និយមហៅ លើសពី ៤ |

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០១...សហវ.ពស

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កុម្ភៈ - ឆ្នាំ២០០៦

លិខិតចូល
ថ្ងៃទី ០៥ ខែ ៣ ឆ្នាំ២០០៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៦

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទមេត្តាជ្រាបថា : ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៦ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៦ ។

<u>ពន្ធនេះត្រូវបានលើកលែងមិនប្រមូលចំពោះ</u> :

- រថយន្តសង្គ្រោះបន្ទាន់ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះរបស់ស្ថានទូត កុងស៊ុល អង្គការ ឬបុគ្គលដែលមានលក្ខន្តិកៈជាអ្នកការទូត ឬកុងស៊ុល ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៦ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៥ សំរាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ រួចហើយ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបញ្ជាក់ពីការបានបង់ពន្ធឆ្នាំ២០០៥ ទេនោះ ត្រូវបង់ពន្ធសំរាប់ឆ្នាំ២០០៥ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៦។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនិមួយៗ ត្រូវបានទទួលប័ណ្ណបង់ពន្ធមួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនិមួយៗ និង បង្កាន់ដៃបង់ពន្ធមួយសន្លឹកទៀត ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
2, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៦ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៦ តទៅ ។

ការត្រួតពិនិត្យនេះ និង ត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយ ក្នុងភូមិ ឃុំ សង្កាត់ ... និង ទីចំណតនានា ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាប្រញាប់ប្រញាល់រួសរាន់អញ្ជើញទៅបង់ពន្ធនេះអោយបានមុនថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៦ កុំបីខាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៥៨ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី.........ខែ..........ឆ្នាំ20.....

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេស គ្រុប**
**KAS GROUP Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8407/06P** ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **SHIN SUNG HO** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ឈឹម ណារិទ្ធ** អភិបាល
លោក **KIM CHONG GU** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣១ ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសបូមដី ផលិតនិងចំរាញ់ប្រេង - ឧស្ម័ន- ស្ថានីយ៍ប្រេង- ផលិតនិងចែកចាយថាមពលអគ្គីសនី
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើការនៅក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ ស៊ីឌី

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋមន្ត្រីស្តីទី

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ ✓
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៦០ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី.........ខែ..........ឆ្នាំ20.....

**ផុសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឌ្រីម មេកឃើរ**
**DREAM MAKERS Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8417/06P** ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឆេព ខេមរា** ប្រធានក្រុមប្រឹក្សាភិបាល
លោក **TRAIRONG CHADUANG** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ២៨៣ H1 ផ្លូវលេខ៦ A សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូល និងលក់រថយន្ត នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ VCD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ហត្ថលេខា និងត្រា

**ចាម ប្រសិទ្ធ**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៦១ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦

បើកឯកទិត
ថ្ងៃទី.........ខែ.........ឆ្នាំ20.....

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេចធ៍ ស្តារ ម៉ាញនីង**
**EIGHT STAR MINING LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8412/06P** ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ចម ចូរ៉យ** ប្រធានក្រុមប្រឹក្សាភិបាល
លោក KOS VASO អភិបាល
លោក KANASEN A MUTHIAH អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥៨ B ផ្លូវលេខ ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ធ្វើអាជីកម្មរុករក និងផលិតរ៉ែ ( ពិសេសនាំចូលឧបករណ៍រុករករ៉ែ និងផលិតរ៉ែ )
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD, VCD & DVD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -ស្តុកបញ្ញើ និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស្តីទី**

**គឹម_ស៊ីថន**

**<u>ចំលងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៦៤ ពណ.នគក

ភ្នំពេញថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី.........ខែ.........ឆ្នាំ២០.....

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **យ៉ាំង ដ្រេហ្គន អ៊ីមផិច**

**YOUNG DRAGON IMPEX Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2757/06E** ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **LIM SOON HENG**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៦ BEo. ផ្លូវលេខ ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ស្តុកទំនិញ និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ប.ក រដ្ឋមន្ត្រីស្តីទី

គីម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៣៦៥ ពណ.នគក

ភ្នំពេញថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី.........ខែ.........ឆ្នាំ20.....

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ផូស្វេត & ខេមីខល (ខេមបូឌា)**
**PHOSPHATE & CHEMICAL ( CAMBODIA ) Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2760/06E** ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **POONPERM APICHITVITAYA** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **SARANPHORN APICHITVITAYA** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៥៩ ផ្លូវលេខ ២៧៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទមនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារធ្វើជូនអតិថិជនក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនឥវ៉ាន់ទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ .

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋមន្ត្រីស្តីទី

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
